ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាជាតិកសិកម្មព្រែកលៀប



# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ

ភ្នំពេញ មករា ២០០៧

# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ

***បទពិសោធន៍សម្រាប់បង្កើនទិន្នផលដំណាំ***


រៀបចំដោយក្រុមពិសោធន៍ :

| | | |
|---|---|---|
| ផាត់ | មុនី | ប្រធានក្រុមពិសោធន៍ ដឹកនាំ និងកែសម្រួលរបាយការណ៍ |
| សុខគួន | គួនសុភ័ក្ត្រ | សមាជិកក្រុមពិសោធន៍ |
| ហួត | ម៉ាលីម | សមាជិកក្រុមពិសោធន៍ |



ម.ព.ឯ.ក AIDOC
Code: 176-001
Date:
Donated by:



សាលាជាតិកសិកម្មព្រែកលៀប មករា ២០០៧

# អារម្ភកថា

ការសិក្សាបានអនុវត្តក្នុងរូបភាពជាការពិសោធន៍សមូហកម្ម (Collection) ដំណាំចេកដែលបានមកពីពូជ ចំនួន ២៣ មុខ ។ កូនចេក ២៣ មុខនេះត្រូវបានបណ្តុះឡើងដោយជាលិកា និងនាំចូលមកពីប្រទេសបែលហ្ស៊ិក ។ តាមប្រវត្តិកូនចេកនាំចូលនេះ ភាគច្រើនមានប្រភពមកពីអាហ្វ្រិក ។ ដោយឡែកក្នុងការសិក្សានេះ ពូជចេកក្នុងស្រុកចំនួន ០៣ មុខក៏ត្រូវបានដាំសម្រាប់ជាកសិណ ។

គោលបំណងសំខាន់ក្នុងការសិក្សា គឺផ្តោតទៅលើភាពស៊ាំក្សេត្រ-បរិស្ថានក្នុងការលូតលាស់ ការផ្តល់ផល និងគុណភាពរស់ជាតិផ្លែចេករបស់ដំណាំចេកទាំង ២៦ ពូជ ។ ទន្ទឹមនេះដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការព័ត៌មាន សំខាន់ៗពាក់ព័ន្ធនឹងលក្ខណៈជីវសាស្ត្ររបស់ដំណាំចេកទូទៅ ទិន្នន័យនិងព័ត៌មានសំខាន់ៗដែលកើតមានក្នុងកម្លុងពេលពិសោធន៍ ត្រូវបានប្រមូល វិភាគតាមស្ថិតិវិទ្យា និងចងក្រងជារបាយការណ៍នេះឡើង ។

របាយការណ៍នេះគ្រាន់តែជាមូលដ្ឋានព័ត៌មានដើមក្នុងតំបន់និងពេលវេលាកំណត់មួយប៉ុណ្ណោះ ដែលទាមទារការសិក្សាបន្តទៀត ។ ដូច្នេះគ្រប់មតិយោបល់ផ្សេងៗពាក់ព័ន្ធ នឹងលទ្ធផល វិធីសាស្ត្រពិសោធន៍ ក៏ដូចជាខ្លឹមសារដែលបានអធិប្បាយក្នុង របាយការណ៍នេះ ត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅ ។

**ក្រុមពិសោធន៍សាលាជាតិកសិកម្មព្រែកលៀប**

**ភ្នំពេញ. មករា ២០០៧**

# មាតិកា

ទំព័រ


១.ស្ថានភាពទូទៅ ............................................................................................01

២. វិធីសាស្ត្រពិសោធន៍ ......................................................................................0៣

២.១. ទីកន្លែងនិងពេលវេលា ..........................................................................0៣

២.២ អំពីប្រភេទដី .........................................................................................0៣

២.៣ វិធីសាស្ត្រពិសោធន៍ ..................................................................................0៣

២.៤ ការរៀបចំប្លុកពិសោធន៍ ..............................................................................0៣

២.៥ ការងារអុវត្តន៍ ........................................................................................0៦

២.៥.១ ពូជ ..................................................................................................0៦

២.៥.២ ការរៀបចំដី .................................................................................... 0៦

២.៥.៣ ការដាំដុះ ..........................................................................................0៧

២.៥.៤ ការស្រោចស្រព ...................................................................................0៧

២.៥.៥ ការថែទាំ ...........................................................................................0៧

២.៥.៦ ការដាក់ជី ..........................................................................................0៧

៣ លទ្ធផល និងការពិភាក្សា ...........................................................................0៨

៣.១ លទ្ធផល

៣.១.១ កំពស់ដើម ........................................................................................0៨

៣.១.២ ប្រវែងស្លឹក .........................................................................................0៩

៣.១.៣ ចំនួនស្លឹក .......................................................................................... ១១

៣.១.៥ ចំនួនផ្លែក្នុង ១ស្និត ................................................................................ ១៣

៣.១.៦ ចំនួនផ្លែក្នុង ១ ស្ទង ..................................................................................១៥

៣.១.៧ ចំនួនកូនបែក ........................................................................................១៦

៣.១.៨ រយៈពេលចាប់ពីថ្ងៃដាំរហូតដល់ចេញត្រយូង ..................................................១៧

៣.១.៩ រយៈពេលចាប់ពីថ្ងៃដាំធ្លាក់ត្រយូងរហូតដល់ទុំ ..................................................១៩

៣.១.១០ រយៈពេលចាប់ពីថ្ងៃដាំរហូតដល់ទុំ ................................................................២០

៣.១.១១ ទម្ងន់ផ្លែក្នុងមួយផ្លែ ...............................................................................២១

៣.១.១២ ទម្ងន់ផ្លែក្នុងមួយស្ទង ..............................................................................២៣

៣.២ ពិភាក្សា ..................................................................................................២៤

សេចក្ដីសន្និដ្ឋាន.............................................................................................២៥

## ខ្លឹមសារសង្ខេប

ការសិក្សាដំណាំចេកត្រូវបានអនុវត្តនៅក្នុងសាលាជាតិកសិកម្មព្រែកលៀបដែលចាប់ផ្តើមពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ ដល់ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦ ។ ការរៀបចំប្លង់ពិសោធន៍ត្រូវបានរៀបចំឡើងដោយ ចាប់ឆ្នោតដោយពេញលិញ (RCBD) ដែលមាន ៣ គុម្ព ២៦ ពូជ ដោយដាំក្នុងទំហំប្លុក ៤ ម × ៣ ម ហើយក្នុង ១ ប្លុកមាន ៣ ដើម និងមាន ២៦ ពូជ ។ ការស្រង់ទិន្នន័យគឺមាន : កំពស់ដើម ប្រវែងស្លឹក ចំនួនស្លឹក ចំនួនកូនបែក, ថ្ងៃខែចេញត្រយូង រយៈពេលលូតលាស់ពីដាំដល់ផ្លែ ទម្ងន់ផ្លែក្នុង១ផ្លែ ទម្ងន់ផ្លែក្នុង១ស្និង គិតជាគីឡូក្រាម ប្រវែងផ្លែ គិតជាសង់ទីម៉ែត្រ ចំនួនផ្លែក្នុង១ស្និតនិង ចំនួនស្និតក្នុង ១ ស្និង។

**លទ្ធផលពិសោធន៍បានបង្ហាញឱ្យឃើញថា :**

- ពូជដែលមានកំពស់ខ្ពស់ជាងគេគឺ ពូជលេខ ២៥ ហើយពូជដែលមាន កំពស់ទាបជាងគេគឺ ពូជលេខ ១២
- ពូជដែលមានប្រវែងស្លឹកវែងជាងគេគឺពូជលេខ ១១ ហើយពូជដែលមានកំពស់ទាបជាងគេគឺ ពូជលេខ ១៥
- ពូជដែលមានចំនួនស្លឹកច្រើនជាងគេគឺពូជលេខ ២ ហើយពូជដែលមានចំនួនស្លឹកតិចជាងគេគឺពូជលេខ ២១
- ពូជដែលមានប្រវែងផ្លែវែងជាងគេគឺពូជលេខ ១៨ ហើយពូជដែលមានប្រវែងផ្លែខ្លីជាងគេគឺពូជលេខ ២៤
- ពូជដែលមានចំនួនផ្លែច្រើនជាងគេគឺពូជលេខ ១៣ ហើយពូជដែលមានចំនួនផ្លែតិចជាងគេគឺពូជលេខ ១៣
- ពូជដែលមានចំនួនកូនបែកច្រើនជាងគេគឺពូជលេខ ៧ ហើយពូជដែលមានចំនួនកូនបែកតិចជាងគេគឺពូជលេខ ៣ និងពូជលេខ ១២
- ពូជដែលមានចំនួនថ្ងៃពីធ្លាក់ត្រយូងដល់ទុំ ឃើញថាពូជដែលមានចំនួនថ្ងៃវែងជាងគេគឺពូជលេខ ១៣ ហើយពូជដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ៣ និងពូជលេខ ២៣
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ចេញត្រយូង ឃើញថាពូជដែលមានចំនួនថ្ងៃវែងជាងគេគឺពូជលេខ ១១ ហើយពូជ ដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ២៤
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ចេញត្រយូង ឃើញថាពូជដែលមានទម្ងន់ធ្ងន់ជាងគេគឺពូជលេខ ៥ ហើយពូជដែលមានទម្ងន់ស្រាលជាងគេគឺ ពូជលេខ ២
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ទុំ ឃើញថាពូជដែលមានរយៈពេលវែងជាងគេគឺពូជលេខ ៦ ហើយពូជដែលមានរយៈពេលខ្លីជាងគេគឺ ពូជលេខ ២ ។

ដូច្នេះការដាំចេកដែលចង់បានអាយុកាលខ្លី គួរយកពូជលេខ ២ បើចង់បានចេកដែលមានផ្លែវែងល្អ គួរយកពូជចេកលេខ ១៨ ចំពោះចំនួនផ្លែចេកច្រើនហើយផ្លែល្អក្នុង ១ ស្និង គួរយកពូជលេខ ១៣ និងពូជដែលមានរសជាតិ ឆ្ងាញ់ជាងគេគឺ ពូជលេខ ៤ (រសជាតិផ្អែម ក្លិនក្រអូបឈ្ងុយស្រាល) ពូជលេខ ៧ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ១០ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ២០ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ១៥ (រសជាតិផ្អែមស្រាល) ។

# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ

## ១. ស្ថានភាពទូទៅ

ដំណាំចេកស្ថិតនៅក្នុងគ្រួសារ Musaceae ។ ផ្លែចេកជាចំណីអាហារមួយដែលប្រជាពលរដ្ឋពិភពលោកនិយមបំផុត ។ គេអាចឃើញដើមចេកនៅគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា ។

ចេកដែលពលរដ្ឋនិយមដាំច្រើនជាងគេមានចេកណាំវ៉ា ចេកអំបូង និង ចេកពងមាន់។ ក្រៅពីពូជទាំង ៣ នេះ យើងសង្កេតឃើញប្រជាពលរដ្ឋដាំពូជផ្សេងៗទៀតដែរដូចជា : ចេកនួន ចេកទឹក ចេកស្នាប់មុខ ចេកជ្វា ចេកមាសស្លួន ចេកអត់គ្រាប់យូងជាដើម ។

ចេកជាដំណាំហូបផ្លែមួយដែលប្រជាជនកម្ពុជាក៏ដូចជាមនុស្សនៅក្នុងពិភពលោកទាំងមូលនិយមបរិភោគ ជាបង្អែម ជាអាហារប្រចាំថ្ងៃបន្ទាប់បន្សំ និងកែច្នៃធ្វើជានំផ្សេងៗ ពិសេសជាអង្ករនៅប្រទេសមួយចំនួនក្នុងទ្វីបអាហ្វ្រិក ។

ចំពោះប្រទេសកម្ពុជា ប្រជាជនភាគច្រើនបរិភោគផ្លែចេកជាចំណីបន្ទាប់បន្សំ ឬ ជាបង្អែម ហើយក៏អាចកែច្នៃសំរាប់ធ្វើជាម្ហូបអាហាររួមផ្សំបានជាច្រើនផងដែរ ។ ផ្លែចេកផ្តល់ថាមពល និងជីវជាតិជាច្រើន ។ នៅក្នុងផ្លែចេកមានជីវជាតិ មួយចំនួនដែលរាងកាយយើងត្រូវការដូចជា កាល់ស្យូម ម៉ាញ៉េស្យូម ហ្វូស្វ័រ ស្ពាន់ធ័រ ។ល។

វេជ្ជសាស្ត្របានប្រើប្រាស់ចេកក្នុងការព្យាបាលជម្ងឺច្រើនមុខ ជាពិសេសមានឥទ្ធិពលល្អប្រសើរក្នុងការព្យាបាលជម្ងឺរលាកពោះវៀន ក្រពះ ធ្វើអោយជម្ងឺផ្សេងៗឆាប់ជាសះស្បើយ ហើយក៏អាចព្យាបាលជម្ងឺរលាកតំរងនោម រលាកសន្លាក់ឆ្អឹង និងជាចំណីយ៉ាងប្រសើរសំរាប់អ្នកជម្ងឺខ្សោះឈាម ព្រោះក្នុងផ្លែចេកមានក៏រិតជាតិដែកខ្ពស់ ។ ទន្ទឹមនឹងនេះផងដែរ ចេកបានត្រូវគេប្រើប្រាស់ក្នុងការព្យាបាលជម្ងឺរាគមួល ហើយដែលអាចផ្តល់ប្រសិទ្ធភាពបានយ៉ាងល្អប្រសើរ ។

ជាទូទៅ ដំណាំចេកអាចដុះលូតលាស់បានលើដីដែលមាន pH ពី ៤ ដល់ ៨ ។ ប៉ុន្តែជាការប្រសើរ ដីដែលមាន pH ពី ៦ ដល់ ៧.៥ គឺជាដីសមស្របសំរាប់ដំណាំនេះ និងអាចផ្តល់ផលខ្ពស់ ។

ចេកជាដំណាំមួយដែលត្រូវការដីដែលមានជីជាតិល្អ ពិសេសជាតិអាហ្សូត និង ប៉ូតាស្យូម ។ ចេកអាចផ្តល់ទិន្នផលដល់ទៅ ៤០ តោនក្នុងមួយហិកតា ។ ដូច្នេះភាពចាំបាច់ណាស់សំរាប់ដំណាំនេះ គឺដីដែលមានជីជាតិច្រើន ឬជាការចាំបាច់ត្រូវដាក់ជីបន្ថែមឱ្យបានសមស្របតាមតម្រូវការរបស់ដំណាំនេះ ។

ដោយឡែកចំណាប់អារម្មណ៏នៃការប្រើប្រាស់ពូជចេកត្រូវបានកត់ត្រា ទៅតាមចំណង់ចំណូលចិត្តរបស់អ្នកបរិភោគ អាចមិនអាស្រ័យទៅនឹងទំហំនៃទិន្នផលទេ ។ បើប្រៀបធៀបទៅនឹងតម្លៃសេដ្ឋកិច្ច ពូជចេកមានគុណភាពអាចផ្តល់កំរៃខ្ពស់ជាងពូជដែលមានទិន្នផលខ្ពស់លើផ្ទៃដីមួយឯកតាដូចគ្នា ។ ប៉ុន្តែបច្ចុប្បន្ននេះពុំទាន់មានការសិក្សាណាមួយឱ្យបានច្បាស់តាមស្ថានភាពភូមិសាស្ត្រ និង ក្សេត្រ-បរិស្ថាន ថាពូជណាមួយអាចផ្តល់គុណភាពល្អដែលជាទីពេញចិត្ត និងផ្តល់ទិន្នផលខ្ពស់ឆ្លើយតបទៅនឹងបរិមាណត្រូវការនៅទីផ្សារនៅឡើយ ។ អាស្រ័យហេតុនេះ ក្រោមកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CARDI) កម្ពុជា សាលាជាតិកសិកម្មព្រែកលៀបបាន ទទួលពូជនាំចូលពីប្រទេសបែលហ្ស៊ិកចំនួន ២៣ ពូជមកសិក្សាពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CARDI) ។

ប្រធានបទ " ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរស់ជាតិ " ត្រូវបានក្រុមពិសោធន៍របស់សាលាជាតិយកមកសិក្សា ។

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះត្រូវបានអនុវត្តក្នុងគោលបំណង :

- ការដុះលូតលាស់របស់ពូជនីមួយៗក្នុងលក្ខខណ្ឌសាលាជាតិកសិកម្មព្រែកលៀប
- សមាសភាពទិន្នផលនៃពូជនីមួយៗ
- ទិន្នផលនៃពូជនីមួយៗ ។

## ២. វិធីសាស្ត្រពិសោធន៍

### ២.១. ទីកន្លែងនិងពេលវេលា

ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៦ A រាជធានីភ្នំពេញ ។ ដោយឡែកតំបន់ដែលធ្វើការសិក្សាស្រាវជ្រាវដំណាំចេក ស្ថិតនៅសាលាជាតិកសិកម្មព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ សាលាជាតិកសិកម្មព្រែកលៀបមានព្រំប្រទល់ជាប់នឹង : ខាងត្បូងទល់ នឹងភូមិព្រែកខ្ចិត ខាងជើងជាប់នឹងវត្តខ្វរ ខាងកើតជាប់ដងទន្លេមេគង្គ ខាងលិចជាប់បឹងដោយមានផ្លូវជាតិលេខ ៦A ឆ្លងកាត់ស្ពានមិត្តភាពកម្ពុជា ជប៉ុន ទៅកាន់ខេត្តនានាដូចកំពង់ចាមជាដើម ។ កន្លែងពិសោធន៍មានផ្ទៃដី ១.២៤៨ម$^2$ នៅក្នុងកសិដ្ឋានដំណាំលំអ និងកសិដ្ឋានដំណាំបន្លែនៃសាលាជាតិកសិកម្ម ព្រែកលៀប ។

ការងារពិសោធន៍នេះត្រូវបានចាប់ផ្តើមពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ និងត្រូវបានបញ្ចប់នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦ ។

### ២.២ អំពីប្រភេទដី

ដីពិសោធន៍ស្ថិតនៅក្នុងស្ថានីយ៍ នៃសាលាជាតិកសិកម្មព្រែកលៀបនេះ និងស្ថិតនៅក្នុងក្រុមទី ៧ តាមប្រព័ន្ធក្រេស្រ្ត-បរិស្ថានទី ២ មាន pH ៦.២-៦.៨ ។ ជាប្រភេទដីល្បប់ តំណាងឱ្យដីភាគច្រើន នៃតំបន់ស្ថិតនៅតាមដងទន្លេមេគង្គ។

### ២.៣ វិធីសាស្ត្រពិសោធន៍

តំរោងពិសោធន៍នេះរៀបចំឡើងសំរាប់សិក្សាតាមដានការលូតលាស់តាមវិធីសាស្ត្រសមូហកម្ម (Collection) ដែលមាន :

**កត្តា : ពូជ**

- មាន ២៦ ពូជ (ចេកខ្មែរ ៣ ពូជ /ពូជបែបអ៊្រិក ២៣ ពូជ) ។

**ចំនួនគុម្ពមាន :**

- ៣ គុម្ព ។

### ២.៤ ការរៀបចំប្លុកពិសោធន៍

ពិសោធន៍រៀបចំឡើងតាមស្ថិតិវិទ្យាក្នុងលក្ខណៈពិសោធន៍សមូហកម្ម ( Collecttion )

- ពិសោធន៍មានចំនួន ២៦ ពូជ និង ៣សារ
- ទំហំប្លុក : ៤ម × ៣ម = ១២ម$^2$
- ចំនួនដើមក្នុងមួយប្លុក : ៣ដើម ( គុម្ព )
- ចំនួនប្លុក ២៦ ( ២៦ ពូជ) ស្មើនឹង ៧៨ ដើម ( គុម្ព )
- ទំហំដីពិសោធន៍សរុប : ១.២៤៨ម$^2$ (៣៩ម × ៣២ម)

## ឈ្មោះពូជចេកពិសោធន៍

| ល.រ | ITC Code | Accesion name | Source |
|---|---|---|---|
| 1. | ITC.0312 | Pisang Jari Buaya | Belgium |
| 2. | ITC.0504 | FHIA-01 | Belgium |
| 3. | ITC.0505 | FHIA-02 | Belgium |
| 4. | TC.0506 | FHIA-03 | Belgium |
| 5. | ITC.0570 | Wlliams (Bell,South Johnstone) | Belgium |
| 6. | ITC.0643 | Cachaco | Belgium |
| 7. | ITC.0712 | Aacv Rose | Belgium |
| 8. | ITC.1122 | Gros-Michel | Belgium |
| 9. | ITC.1123 | Yamyambi KH5 | Belgium |
| 10. | ITC.1264 | FHIA-17 | Belgium |
| 11. | ITC.1265 | FHIA-23 | Belgium |
| 12. | ITC.1282 | GCTCV-119 | Belgium |
| 13. | ITC.1283 | SH 3436-9 | Belgium |
| 14. | ITC.1296 | TMBx 5295-1 | Belgium |
| 15. | ITC.1297 | TMBx 5295-1 | Belgium |
| 16. | ITC.1307 | SH-3640 | Belgium |
| 17. | ITC.1319 | FHIA 18 | Belgium |
| 18. | ITC.1332 | FHIA 21(#68) | Belgium |
| 19. | ITC.1344 | CABP 39 | Belgium |
| 20. | ITC.1418 | FHIA 25 | Belgium |
| 21. | ITC.1441 | Pisang Ceylan | Belgium |
| 22. | ITC.1442 | GCTCV-106 | Belgium |
| 23. | ITC.1443 | GCTCV-247 | Belgium |
| 24. | Acc. Local | Chek Pong Mean (Local Check) | Cambodia |
| 25. | Acc. Local | Chek Namva (Local Check) | Cambodia |
| 26. | Acc. Local | Chek Am Baung (Local Check) | Cambodia |

* ពូជចេកទាំង ២៦ ពូជ ខាងលើបានមកពីការបណ្តុះជាលិកា ។

# ប្លង់ពិសោធន៍សម្ភារកម្មពូជចេក

## នៅសាលាជាតិកសិកម្មព្រែកលៀប រដូវវស្សា ឆ្នាំ ២០០៥

| សារធី ១ | | សារធី ២ | | សារធី ៣ | |
|---|---|---|---|---|---|
| * V១ * (4m) | * V១៤ * | * V២២ * (4m) | * V៣ * | * V៦ * | * V២៥ * |
| * V២ * | * V១៥ * | * V១២ * | * V១៩ * | * V១២ * | * V១៧ * |
| * V៣ * | * V១៦ * | * V២ * | * V១០ * | * V១ * | * V៣ * |
| * V៤ * | * V២៦ * | * V១៣ * | * V៦ * | * V២៣ * | * V៨ * |
| * V៥ * | * V២៥ * | * V៩ * | * V១៥ * | * V២០ * | * V២១ * |
| * V៦ * | * V២៤ * | * V១៨ * | * V២០ * | * V១៣ * | * V១១ * |
| * V៧ * | * V២៣* | * V២៦ * | * V៧ * | * V៩ * | * V១៨ * |
| * V៨ * | * V២២ * | * V១៧ * | * V២៣ * | * V២ * | * V៤ * |
| * V៩ * | * V២១* | * V៤ * | * V១៦ * | * V១៥ * | * V១៣ * |
| * V១០ * | * V២០* | * V៨ * | * V១១ * | * V១៩ * | * V៥ * |
| * V១១ * | * V១៩ * | * V១៤ * | * V២៥ * | * V៤ * | * V២៤ * |
| * V១២ * | * V១៨ * | * V៥ * | * V១ * | * V៧ * | * V១៦ * |
| * V១៣ * | * V១៧ * | * V២៤ * | * V២១ * | * V១៧ * | * V២៦ * |

២៦ ម

៣៦ ម

-កំណត់សំគាល់ :  V : varities

## ២.៥ ការខារអូចគ្គន៍

### ២.៥.១ ពូជ

- ២៣ ពូជ នាំចូលពីប្រទេសបែលហ្សិក
- ៣ ពូជនៅក្នុងស្រុកខ្មែរ : ពូជចេកពងមាន់ ពូជចេកអំបូង ពូជចេកណាំវ៉ា





រូបថត ១ : ពូជចេកនាំចូល ២៣ ពូជ និងពូជក្នុងស្រុក ៣ ពូជ

### ២.៥.២ ការរៀបចំដី

មុនពេលរៀបចំប្លង់ពិសោធន៍ ដីត្រូវបានបំបែកឱ្យម៉ដ្ឋល្អ ទើបរៀបចំជាប្លង់ពិសោធន៍ទៅតាមបច្ច័យនីមួយៗ នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥ ។



រូបថត ២ : ការរៀបចំដី

២.៥.៣ ការដាំដុះ

ពូជចេកដែលត្រូវធ្វើការដាំដុះ ត្រូវបានត្រៀមទុកជាស្រេច និង បានធ្វើការរៀបចំផ្លាកសញ្ញាទៅតាមពូជនៃរណ្ដៅនីមួយៗ ។ ក្រោយពីបានដាំរួចរាល់ហើយត្រូវធ្វើការស្រោចទឹក និង យកចាងដូង រឺ ក៏ឈើមកដោតជុំវិញដើម្បីការពារការដួលនៅពេលភ្លៀង ខ្យល់ ។





រូបថត ៣ : សកម្មភាពដាំចេក

២.៥.៤ ការស្រោចស្រព

ការដាំដុះនៅរដូវវស្សា មិនចាំបាច់ធ្វើការស្រោចស្រពរាល់ថ្ងៃនោះទេ ។ ក្នុងករណីអត់ភ្លៀង ២ សប្ដាហ៍ឡើងទៅ ទើបធ្វើការស្រោចស្រព។

២.៥.៥ ការថែទាំ

នៅពេលស្មៅដុះច្រើនការជម្រះបំផុសដីយកស្មៅចេញឱ្យអស់ ។ ចំពោះចេកស្លឹកដែលងាប់ជាប់នឹងដើមត្រូវបានយកកាំបិតកាត់ស្លឹកនោះចេញ ។

២.៥.៦ ការដាក់ជី

ជី ១៥.១៥.១៥ ( ២០០ គ.ក្រ / ហិចតា ) ដាក់មុនដាំមួយរយភាគរយ ។

## ៣.១ លទ្ធផល និងការពិភាក្សា

### ៣.១.១ កំពស់ដើម

ការស្រង់ទិន្នន័យត្រូវបានធ្វើឡើងក្រោយពីដាំបានរយៈពេល១សប្ដាហ៍ ។ ចំនួនដងនៃ ហើយការស្រង់ទិន្នន័យនេះគឺស្រង់ ១ ខែ ២ ដង ក្នុងរយៈពេល ១៣ ខែ ដោយយកទិន្នន័យទាំង ១៣ ខែ មកបូកសរុបរកមធ្យម ។ ក្នុងការតាមដាននេះ យើងឃើញថា កំពស់របស់ដើមចេកមានការលូតលាស់ មិនដូចគ្នាទេ ។

តារាង ១ : កំពស់ដើម

| ពូជ | លេខកូដ | មធ្យម (ម) |
|---|---|---|
| ១ | ០៣១២ | ២.៨៩ |
| ២ | ០៥០៤ | ១.៨៤ |
| ៣ | ០៥០៥ | ១.៥៣ |
| ៤ | ០៥០៦ | ២.៧២ |
| ៥ | ០៥៧០ | ១.៧៥ |
| ៦ | ០៦៤៣ | ២.៥៥ |
| ៧ | ០៧១២ | ២.៥៨ |
| ៨ | ១១២២ | ៣.៣៤ |
| ៩ | ១១២៣ | ២.៥១ |
| ១០ | ១២៦៤ | ២.១០ |
| ១១ | ១២៦៥ | ២.៨៦ |
| ១២ | ១២៨២ | ១.៥៩ |
| ១៣ | ១២៨៣ | ២.៤៩ |
| ១៤ | ១២៩៦ | ២.៨៣ |
| ១៥ | ១២៩៧ | ២.៦១ |
| ១៦ | ១៣០៧ | ២.៤២ |
| ១៧ | ១៣១៩ | ២.២៧ |
| ១៨ | ១៣៣២ | ២.៧៩ |
| ១៩ | ១៣៤៤ | ២.៥២ |
| ២០ | ១៤១៨ | ២.២៧ |
| ២១ | ១៤៤១ | ២.៥៦ |

| | | |
|---|---|---|
| ២២ | ១៤៤២ | ២.២២ |
| ២៣ | ១៤៤៣ | ១.៦៣ |
| ២៤ | ពងមាន់ | ១.៨១ |
| ២៥ | ណាំ វ៉ា | ៣.៥២ |
| ២៦ | អំបូង | ២.៨៣ |
| មធ្យម | | **២.៤២** |

ក្នុងតារាង ១ ខាងលើ គេអាចកត់សម្គាល់ថា :

- កំពស់ដើមដែលទាបជាងគេគឺ ពូជលេខ ១២ គឺកំពស់ ១.៥៩ ម
- កំពស់ដើមជាមធ្យមប្រមាណ ២.៥៥ ម គឺពូជលេខ ១២ និងពូជលេខ ២៥
- កំពស់ដើមដែលខ្ពស់ជាងគេគឺ ពូជលេខ ២៥ មានកំពស់ ៣.៥២ ម
- កំពស់ដើមជាមធ្យមទាំង ២៦ ពូជ គឺ ២.៤២ ម
- ឯពូជក្នុងស្រុកទាំង ៣ មិនមានកំពស់ទាបជាងពូជនាំចូល និងពូជចេកណាំវ៉ាខ្ពស់ជាងគេទាំងអស់ ។

កំពស់ដើមបានបង្ហាញឃើញថា ពូជដែលមានកំពស់ខ្ពស់ជាងគេគឺ ពូជលេខ ២៥ និងពូជដែលមានកំពស់ទាបជាងគេគឺ ពូជលេខ ១២ ។

### ៣.១.២ ប្រវែងស្លឹក

ការស្រង់ទិន្នន័យនេះធ្វើឡើងក្រោយពីដាំបានរយៈពេល១សប្តាហ៍ ហើយការស្រង់ទិន្នន័យនេះគឺស្រង់ ១ ខែ ២ ដង ក្នុងរយៈពេល ១៣ ខែ ។ ក្នុងការតាមដាននេះយើងឃើញថា ប្រវែងរបស់ស្លឹកចេកមានការលូតលាស់ មិនដូចគ្នាទេ ។

**តារាង ២ : ប្រវែងស្លឹក**

| **ល.រ** | **លេខកូដ** | **មធ្យម (ម)** |
|---|---|---|
| ១ | ០៣១២ | ១.៣៧ |
| ២ | ០៥០៤ | ១.៥១ |
| ៣ | ០៥០៥ | ១.៣១ |
| ៤ | ០៥០៦ | ១.៣៨ |
| ៥ | ០៥៧០ | ១.០៦ |
| ៦ | ០៦៤៣ | ១.៣៥ |
| ៧ | ០៧១២ | ១.២០ |
| ៨ | ១១២២ | ១.៤០ |

| | | |
|---|---|---|
| ៩ | ១១២៣ | ១.៥១ |
| ១០ | ១២៦៤ | ១.៤០ |
| ១១ | ១២៦៥ | ១.៧៣ |
| ១២ | ១២៨២ | ១.១៥ |
| ១៣ | ១២៨៣ | ១.៧០ |
| ១៤ | ១២៩៦ | ១.២០ |
| ១៥ | ១២៩៧ | ០.៩៤ |
| ១៦ | ១៣០៧ | ១.១៦ |
| ១៧ | ១៣១៩ | ១.១៣ |
| ១៨ | ១៣៣២ | ១.៤២ |
| ១៩ | ១៣៤៤ | ១.២១ |
| ២០ | ១៤១៨ | ១.៥២ |
| ២១ | ១៤៤១ | ១.៣៧ |
| ២២ | ១៤៤២ | ១.០០ |
| ២៣ | ១៤៤៣ | ១.០៧ |
| ២៤ | ពងមាន់ | ១.១៩ |
| ២៥ | ណាំ វ៉ា | ១.៥៨ |
| ២៦ | អំបូង | ១.២០ |
| **មធ្យម** | | **១.៣១** |

ក្នុងតារាង ២ គេអាចកត់សម្គាល់ថា :

- ប្រវែងស្លឹកដែលខ្លីជាងគេគឺ ពូជលេខ ១៥ មានប្រវែង ០.៩៤ ម
- ប្រវែងស្លឹកជាមធ្យមប្រមាណ ១.៣៣ ម គឺពូជលេខ ១៥ និងពូជរលេខ ១១
- ប្រវែងស្លឹកដែលវែងជាងគេគឺ ពូជលេខ ១១ មានប្រវែង ១.៧៣ ម
- ប្រវែងស្លឹកជាមធ្យមទាំង ២៦ ពូជ គឺ ១.៣១ ម
- ឯពូជក្នុងស្រុកទាំង ៣ មិនមានប្រវែងខ្លីជាងពូជនាំចូល និងពូជចេកណាំវ៉ាមានប្រវែងវែងជាងគេទាំងអស់ ។

ជារួមពូជដែលមានប្រវែងស្លឹកវែងជាងគេគឺ ពូជលេខ ១១ ។ ពូជ ដែលមានប្រវែងស្លឹកខ្លីជាងគេគឺ ពូជលេខ ១៥ ។

### ៣.១.៣ ចំនួនស្លឹក

ការស្រង់ទិន្នន័យនេះធ្វើឡើងក្រោយពីដាំបានរយៈពេល១សប្តាហ៍។ ការស្រង់ទិន្នន័យនេះគឺស្រង់ ១ ខែ ២ ដង ក្នុងរយៈពេល ១៣ ខែ ។ ចំនួនរបស់ស្លឹកចេកមានការកើនឡើង មិនដូចគ្នាទេ ។

តារាង ៣ : ចំនួនស្លឹក

| ពូជ | លេខកូដ | មធ្យម |
|---|---|---|
| ១ | ០៣១២ | ៣៤.៥ |
| ២ | ០៥០៤ | ៣៧.៥ |
| ៣ | ០៥០៥ | ៣០ |
| ៤ | ០៥០៦ | ២៧.៥ |
| ៥ | ០៥៧០ | ២៦ |
| ៦ | ០៦៤៣ | ៣២.៥ |
| ៧ | ០៧១២ | ២៧ |
| ៨ | ១១២២ | ៣១.៥ |
| ៩ | ១១២៣ | ៣៤ |
| ១០ | ១២៦៤ | ២៧.៥ |
| ១១ | ១២៦៥ | ២៨ |
| ១២ | ១២៨២ | ៣៥ |
| ១៣ | ១២៨៣ | ៣៣ |
| ១៤ | ១២៩៦ | ២៩ |
| ១៥ | ១២៩៧ | ៣០.៥ |
| ១៦ | ១៣០៧ | ២៦.៥ |
| ១៧ | ១៣១៩ | ២៥ |
| ១៨ | ១៣៣២ | ៣២.៥ |
| ១៩ | ១៣៤៤ | ២៤.៥ |
| ២០ | ១៤១៨ | ៣១.៥ |
| ២១ | ១៤៤១ | ២២ |
| ២២ | ១៤៤២ | ២៨.៥ |
| ២៣ | ១៤៤៣ | ៣១.៥ |

| | | |
|---|---|---|
| ២៤ | ពងមាន់ | ៣៤.៥ |
| ២៥ | ណាំ វ៉ា | ២៤ |
| ២៦ | អំបូង | ៣៧ |
| មធ្យម | | ៣០.០៣៨ |

តារាង ៣ បានបង្ហាញថា ៖

- ចំនួនស្លឹកដែលតិចជាងគេគឺ ពូជលេខ ២១ មានចំនួន ២២ សន្លឹក
- ចំនួនស្លឹកជាមធ្យមប្រមាណ ៣០ សន្លឹក គឺពូជលេខ ២១ និងពូជលេខ ២
- ចំនួនស្លឹកដែលច្រើនជាងគេគឺ ពូជលេខ ២ មានចំនួន ៣៧.៥ សន្លឹក
- ចំនួនស្លឹកជាមធ្យមទាំង ២៦ ពូជ គឺ ៣៧ សន្លឹក
- ឯពូជក្នុងស្រុកទាំង ៣ មិនមានចំនួនស្លឹកតិចជាងពូជនាំចូល និងពូជចេកអំបូងមានចំនួនស្លឹកច្រើនជាងគេទាំងអស់ ។

យោងតាមលទ្ធផលនៃការពិសោធន៍ ពូជដែលមានចំនួនស្លឹកច្រើនជាងគេគឺ ពូជលេខ ២ និងពូជដែលមានចំនួនស្លឹកតិចជាងគេគឺ ពូជលេខ ២១ ។

### ៣.១.៤ ប្រវែងផ្លែ

ការស្រង់ទិន្នន័យផ្លែត្រូវបានអនុវត្តនៅពេលផ្លែចេកទុំ ។

**តារាង ៤ ៖ ប្រវែងផ្លែ**

| ពូជ | លេខកូដ | មធ្យម (ស.ម) |
|---|---|---|
| ១ | ០៣១២ | ៩.៥ |
| ២ | ០៥០៤ | ៦.៥ |
| ៣ | ០៥០៥ | ០ |
| ៤ | ០៥០៦ | ១៣.៥ |
| ៥ | ០៥៧០ | ១៥.៥ |
| ៦ | ០៦៤៣ | ១៦.៥ |
| ៧ | ០៧១២ | ១០.៥ |
| ៨ | ១១២២ | ៨.៨៥ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ១៣.៥ |

| | | |
|---|---|---|
| ១១ | ១២៦៥ | 0 |
| ១២ | ១២៨២ | 0 |
| ១៣ | ១២៨៣ | ៧ |
| ១៤ | ១២៩៦ | 0 |
| ១៥ | ១២៩៧ | ២០.៥ |
| ១៦ | ១៣០៧ | ១៤.៥ |
| ១៧ | ១៣១៩ | ១៧.៥ |
| ១៨ | ១៣៣២ | ២៤.៥ |
| ១៩ | ១៣៤៤ | ៩.៥ |
| ២០ | ១៤១៨ | ៦ |
| ២១ | ១៤៤១ | 0 |
| ២២ | ១៤៤២ | ៧ |
| ២៣ | ១៤៤៣ | ៥.២៥ |
| ២៤ | ពងមាន់ | ៤.៦ |
| ២៥ | ណាំ វ៉ា | ៦.១ |
| ២៦ | អំបូង | ១៧.២៥ |
| មធ្យម | | ៩.00១ |

ក្នុងតារាង ៤ ប្រវែងផ្លែបានប្រែប្រួល ៖

- ប្រវែងផ្លែដែលខ្លីជាងគេគឺ ពូជលេខ ២៤ មានប្រវែង ៤.៦ ស.ម
- ប្រវែងផ្លែជាមធ្យមប្រមាណ ១៤.៥៥ ស.ម គឺពូជលេខ ២៤ និងពូជលេខ ១៨
- ប្រវែងផ្លែដែលវែងជាងគេគឺ ពូជលេខ ១៨ មានប្រវែង ២៤.៥ ស.ម
- ប្រវែងផ្លែជាមធ្យមទាំង ២៦ ពូជ គឺ ៩ ស.ម ។

តាមលទ្ធផលខាងលើ ពូជដែលមានប្រវែងផ្លែវែងជាងគេគឺ ពូជលេខ ១៨ ហើយពូជដែល មានប្រវែងផ្លែខ្លីជាងគេគឺ ពូជលេខ ២៤ ។

### ៣.១.៥ ចំនួនផ្លែក្នុងមួយស្ទិក

ការស្រង់ទិន្នន័យផ្លែត្រូវបានអនុវត្តនៅពេលផ្លែចេកចាស់ ដល់ខ្ញុំ ។

តារាង ៥ : ចំនួនផ្លែក្នុងមួយស្ទិត

| ល.រ | លេខកូដ | មធ្យម |
|---|---|---|
| ១ | ០៣១២ | ១២.៧ |
| ២ | ០៥០៤ | ១៣.៣ |
| ៣ | ០៥០៥ | ០ |
| ៤ | ០៥០៦ | ១៥.១ |
| ៥ | ០៥៧០ | ១៧.៥ |
| ៦ | ០៦៤៣ | ៩.៤ |
| ៧ | ០៧១២ | ១៥.៦ |
| ៨ | ១១២២ | ១៤.៣ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ១២.៣ |
| ១១ | ១២៦៥ | ០ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ១៩.៧ |
| ១៤ | ១២៩៦ | ០ |
| ១៥ | ១២៩៧ | ១១.៤ |
| ១៦ | ១៣០៧ | ១៧.៨ |
| ១៧ | ១៣១៩ | ១១.៤ |
| ១៨ | ១៣៣២ | ១៣.៣ |
| ១៩ | ១៣៤៤ | ១២ |
| ២០ | ១៤១៨ | ២១ |
| ២១ | ១៤៤១ | ០ |
| ២២ | ១៤៤២ | ១១.៧ |
| ២៣ | ១៤៤៣ | ១២.៩ |
| ២៤ | ពងមាន់ | ១៥.២ |
| ២៥ | ណាំ វ៉ា | ១៥ |
| ២៦ | អំបូង | ១៥.២ |
| មធ្យម | | ១៤.៣៤ |

ក្នុងតារាង ៥ ចំនួនផ្លែក្នុងមួយស្និត :

- ចំនួនផ្លែក្នុងមួយស្និតដែលច្រើនជាងគេគឺ ពូជលេខ ២០ មានចំនួន ២១ផ្លែ
- ចំនួនផ្លែដែលតិចជាងគេគឺ ពូជលេខ ៦ មានចំនួន ៩.៤ផ្លែ
- ចំនួនផ្លែជាមធ្យមទាំង ២៦ ពូជ គឺ ១៤.៣៤ ។

តាមលទ្ធផលខាងលើ ពូជដែលមានចំនួនផ្លែច្រើនជាងគេគឺ ពូជលេខ ២០ ហើយពូជដែលចំនួនផ្លែតិចជាងគេគឺ ពូជលេខ ៦ ។

### ៣.១.៦ ចំនួនផ្លែក្នុង ១ ស្តូច

ការស្រង់ទិន្នន័យផ្លែក៏ត្រូវបានអនុវត្តនៅពេលផ្លែចេកទុំ ។

តារាង ៦ : ចំនួនផ្លែក្នុង ១ ស្តូច

| ពូជ | លេខកូដ | មធ្យម |
|---|---|---|
| ១ | ០៣១២ | ១០១.៥ |
| ២ | ០៥០៤ | ៤០ |
| ៣ | ០៥០៥ | ០ |
| ៤ | ០៥០៦ | ១៥០.៥ |
| ៥ | ០៥៧០ | ១៧៥ |
| ៦ | ០៦៤៣ | ៣៧.៥ |
| ៧ | ០៧១២ | ៦៩.៥ |
| ៨ | ១១២២ | ៥៨ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ៩៨ |
| ១១ | ១២៦៥ | ០ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ១៧៧.៥ |
| ១៤ | ១២៩៦ | ០ |
| ១៥ | ១២៩៧ | ៩៥.៥ |
| ១៦ | ១៣០៧ | ១៤២.៥ |
| ១៧ | ១៣១៩ | ៩១ |
| ១៨ | ១៣៣២ | ៧៩.៥ |

| | | |
|---|---|---|
| ១៩ | ១៣៤៤ | ៣៦ |
| ២០ | ១៤១៨ | ១២៦.៥ |
| ២១ | ១៤៤១ | ០ |
| ២២ | ១៤៤២ | ៣៥ |
| ២៣ | ១៤៤៣ | ៨០ |
| ២៤ | ពងមាន់ | ៤៥.៥ |
| ២៥ | ណាំ វ៉ា | ១៥១.៥ |
| ២៦ | អំបូង | ១៣៥ |
| មធ្យម | | **៧៤.០៥៧** |

តាមតារាងទិន្នន័យដែលបានសិក្សាតាមដាននេះ គេអាចកត់សម្គាល់ថា :

- ចំនួនផ្លែដែលតិចជាងគេគឺ ពូជលេខ ២២ មានចំនួន ៣៥ ផ្លែ
- ចំនួនផ្លែជាមធ្យមប្រមាណ ២២៣ ផ្លែ គឺពូជលេខ ២២ និងពូជលេខ ១៣
- ចំនួនផ្លែដែលច្រើនជាងគេគឺ ពូជលេខ ១៣ មានប្រវែង ៤១២ ផ្លែ
- ចំនួនផ្លែជាមធ្យមទាំង ២៦ ពូជ គឺ ៨៣ ផ្លែ ។

ពូជដែលមានចំនួនផ្លែច្រើនជាងគេគឺ ពូជលេខ ១៣ ហើយពូជដែល មានចំនួនផ្លែតិចជាងគេគឺ ពូជលេខ ២២ ។

### ៣.១.៧ ចំនួនកូនបែក

ក្រោយពីដាំបានរយៈពេល១សប្តាហ៍ ការស្រង់ទិន្នន័យចំនួនកូនបែកត្រូវបានអនុវត្តក្នុង ១ ខែ ២ ដង ក្នុងរយៈពេល ១៣ ខែ ។ ចំនួនកូនបែករបស់ចេកមានការកើនឡើង និងថយមិនដូចគ្នាទេ ។

**តារាង ៧ : ចំនួនកូនបែក**

| **ពូជ** | **លេខកូដ** | **មធ្យម(ដើម)** |
|---|---|---|
| ១ | ០៣១២ | ៥ |
| ២ | ០៥០៤ | ២ |
| ៣ | ០៥០៥ | ១.៥ |
| ៤ | ០៥០៦ | ៤ |
| ៥ | ០៥៧០ | ៣.៥ |
| ៦ | ០៦៤៣ | ៣ |
| ៧ | ០៧១២ | ៩.៥ |
| ៨ | ១១២២ | ៧ |

| | | |
|---|---|---|
| ៩ | ១១២៣ | ២ |
| ១០ | ១២៦៤ | ៣.៥ |
| ១១ | ១២៦៥ | ៣.៥ |
| ១២ | ១២៨២ | ១.៥ |
| ១៣ | ១២៨៣ | ៥ |
| ១៤ | ១២៩៦ | ៤ |
| ១៥ | ១២៩៧ | ៧.៥ |
| ១៦ | ១៣០៧ | ៦ |
| ១៧ | ១៣១៩ | ៦ |
| ១៨ | ១៣៣២ | ៥ |
| ១៩ | ១៣៤៤ | ៣.៥ |
| ២០ | ១៤១៨ | ៣.៥ |
| ២១ | ១៤៤១ | ៤ |
| ២២ | ១៤៤២ | ៣.៥ |
| ២៣ | ១៤៤៣ | ៣ |
| ២៤ | ពងមាន់ | ៣ |
| ២៥ | ណាំ វ៉ា | ៧.៥ |
| ២៦ | អំបូង | ៥ |
| **មធ្យម** | | **៤.៣២៦** |

តួលេខក្នុងតារាង ៦ បង្ហាញថា :

- ចំនួនកូនបែកដែលតិចជាងគេគឺ ពូជលេខ ៣ និងពូជលេខ ១២ មានចំនួន ១ កូន
- ចំនួនកូនបែកជាមធ្យមប្រមាណ ៥ កូន គឺពូជលេខ ៣ និងពូជលេខ ៧
- ចំនួនកូនបែកដែលច្រើនជាងគេគឺ ពូជលេខ ៧ មានចំនួន ៩ កូន
- ចំនួនផ្លែជាមធ្យមទាំង ២៦ ពូជ គឺ ១៦ កូន ។

យោងតាមលទ្ធផលចំនួនកូនបែកឃើញថា ពូជដែលមានចំនួនកូនបែកច្រើនជាងគេគឺ ពូជលេខ ៧ និងពូជដែលមានចំនួនកូនបែកតិចជាងគេគឺ ពូជលេខ ៣ និងពូជលេខ ១២ ។

### ៣.១.៨ រយៈពេលថ្ងៃចាប់ពីដាំរហូតដល់ចេញត្រយូង

ចំពោះការស្រង់ទិន្នន័យនេះគឺ ស្រងចាប់ពីថ្ងៃដាំដល់ធ្លាក់ត្រយូង ទិន្នន័យដែលទទួលបានមាននៅក្នុងតារាងទី ១០។

**តារាង ៨ : រយៈពេលចាប់ពីដាំរហូតដល់ថ្ងៃចេញត្រយូង**

| កូដ | លេខកូដ | មធ្យម |
|---|---|---|
| ១ | ០៣១២ | ២៥៨.៥ |
| ២ | ០៥០៤ | ១២៨.៥ |
| ៣ | ០៥០៥ | ២៩៨ |
| ៤ | ០៥០៦ | ២៣០ |
| ៥ | ០៥៧០ | ១៧៧.៥ |
| ៦ | ០៦៤៣ | ២៧៥.៥ |
| ៧ | ០៧១២ | ១៩៤.៥ |
| ៨ | ១១២២ | ២៣៥.៥ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ៣០៦ |
| ១១ | ១២៦៥ | ៣៧០.៥ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ៤៦៦.៧៥ |
| ១៤ | ១២៩៦ | ៣១២.៥ |
| ១៥ | ១២៩៧ | ២២២ |
| ១៦ | ១៣០៧ | ២២១ |
| ១៧ | ១៣១៩ | ២០៨ |
| ១៨ | ១៣៣២ | ២៣៤ |
| ១៩ | ១៣៤៤ | ២៨២ |
| ២០ | ១៤១៨ | ១៤៤.៥ |
| ២១ | ១៤៤១ | ១៩៤ |
| ២២ | ១៤៤២ | ២៩៩.៥ |
| ២៣ | ១៤៤៣ | ២៣៩.៥ |
| ២៤ | ពងមាន់ | ១២៥ |

| | | |
|---|---|---|
| ២៥ | ណាំ វ៉ា | ២៨៦.៥ |
| ២៦ | អំបូង | ១៧៧.៥ |
| **មធ្យម** | | **២២៤.៨៥៤** |

គេអាចកត់សម្គាល់ថា :

- រយៈពេលចាប់ពីដាំរហូតដល់ចេញគ្រាប់ដំបូង ដែលខ្លីជាងគេគឺ ពូជលេខ ២៤ មានចំនួន ១២៥ ថ្ងៃ
- រយៈពេលចាប់ពីដាំរហូតដល់ចេញគ្រាប់ដំបូងជាមធ្យមប្រមាណ ២៤៧ ថ្ងៃ គឺពូជលេខ ២៤ និងពូជលេខ ១១
- រយៈពេលចាប់ពីដាំរហូតដល់ចេញគ្រាប់ដំបូងដែលច្រើនជាងគេគឺ ពូជលេខ ១១ មានប្រវែង ៣៧០ ថ្ងៃ
- រយៈពេលចាប់ពីដាំរហូតដល់ចេញគ្រាប់ដំបូងជាមធ្យមទាំង ២៦ ពូជ គឺ ២២៤ ថ្ងៃ ។

យោងតាមលទ្ធផលចំនួនថ្ងៃចាប់ពីដាំរហូតដល់ចេញគ្រាប់ដំបូង ឃើញថាពូជដែលមានចំនួនថ្ងៃវែងជាងគេគឺ ពូជលេខ ១១ នឹងពូជដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ២៤ ។

**៣.១.៩ រយៈពេលពីធ្លាក់គ្រាប់ដំបូងរហូតដល់ខ្ចី**

ការស្រង់ទិន្នន័យនេះបានចាប់ផ្តើមពីថ្ងៃធ្លាក់គ្រាប់ដំបូងរហូតដល់ថ្ងៃផ្លែចេកខ្ចី ។

**តារាង ៩ : រយៈពេលចាប់ពីថ្ងៃធ្លាក់គ្រាប់ដំបូងរហូតដល់ផ្លែចេកខ្ចី**

| **ពូជ** | **លេខកូដ** | **មធ្យម** |
|---|---|---|
| ១ | ០៣១២ | ៤៦ |
| ២ | ០៥០៤ | ៣២.៥ |
| ៣ | ០៥០៥ | 0 |
| ៤ | ០៥០៦ | ៩២ |
| ៥ | ០៥៧០ | ៥៩ |
| ៦ | ០៦៤៣ | ១១៨.៥ |
| ៧ | ០៧១២ | ៦៧.៥ |
| ៨ | ១១២២ | ៧៥.៥ |
| ៩ | ១១២៣ | 0 |
| ១០ | ១២៦៤ | ៥៤.៥ |
| ១១ | ១២៦៥ | 0 |
| ១២ | ១២៨២ | 0 |
| ១៣ | ១២៨៣ | ៩៧.៥ |
| ១៤ | ១២៩៦ | 0 |

| | | |
|---|---|---|
| ១៥ | ១២៩៧ | ១១៦ |
| ១៦ | ១៣០៧ | ៨៩ |
| ១៧ | ១៣១៩ | ១១៩.៥ |
| ១៨ | ១៣៣២ | ៨៧.៥ |
| ១៩ | ១៣៨៤ | ៣៣.៥ |
| ២០ | ១៤១៨ | ៤៥.៥ |
| ២១ | ១៤៤១ | ០ |
| ២២ | ១៤៤២ | ៥៧ |
| ២៣ | ១៤៤៣ | ៤១ |
| ២៤ | ពងមាន់ | ៣៧.៥ |
| ២៥ | ណាំ វ៉ា | ១១៨.៥ |
| ២៦ | អំបូង | ១២៣ |
| មធ្យម | | **៦៨.៧០១** |

- រយៈពេលពីធ្លាក់ត្រយ៉ូងដល់ទុំខ្លីជាងគេគឺ ពូជលេខ ២៣ មានចំនួន ៤១ ថ្ងៃ
- រយៈពេលពីធ្លាក់ត្រយ៉ូងដល់ទុំជាមធ្យមប្រមាណ ២០៦ ថ្ងៃ គឺពូជលេខ ២៣ និងពូជលេខ ១៣
- រយៈពេលពីធ្លាក់ត្រយ៉ូងដល់ទុំដែលវែងជាងគេគឺ ពូជលេខ ១៣ មានចំនួន ៣៧២ ថ្ងៃ
- រយៈពេលពីធ្លាក់ត្រយ៉ូងដល់ទុំជាមធ្យមទាំង ២៦ ពូជ គឺ ៦៨ ថ្ងៃ ។

យោងតាមលទ្ធផល ចំនួនថ្ងៃពីថ្ងៃធ្លាក់ត្រយ៉ូងដលថ្ងៃទុំ ពូជដែលមានរយៈពេលវែងជាងគេគឺ ពូជលេខ ១៣ ហើយពូជ ដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ៣ និងពូជលេខ ២៣ ។

**៣.ខ.១០ រយៈពេលចាប់ពីថ្ងៃដាំរហូតដល់ថ្ងៃទុំ**

ចំពោះការស្រង់ទិន្នន័យនេះគឺ ស្រង់ចាប់ពីថ្ងៃដាំរហូតដល់ថ្ងៃចេកទុំ ទិន្នន័យដែលទទួលបានមាននៅក្នុងតារាង ទី ១០ ។

**តារាង ១០ : រយៈពេលចាប់ពីដាំរហូតដល់ទុំ**

| **ពូជ** | **លេខកូដ** | **មធ្យម** |
|---|---|---|
| ១ | ០៣១២ | ៣០៤.៥ |
| ២ | ០៥០៤ | ១៦១ |
| ៣ | ០៥០៥ | ២៩៨ |
| ៤ | ០៥០៦ | ៣២២ |

| | | |
|---|---|---|
| ៥ | ០៥៧០ | ២៣៦.៥ |
| ៦ | ០៦៤៣ | ៣៩៤ |
| ៧ | ០៧១២ | ២៦២ |
| ៨ | ១១២២ | ៣១១ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ៣៦០.៥ |
| ១១ | ១២៦៥ | ៣៧០.៥ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ៣៨៣ |
| ១៤ | ១២៩៦ | ៣១២.៥ |
| ១៥ | ១២៩៧ | ៣៣៨ |
| ១៦ | ១៣០៧ | ៣១០ |
| ១៧ | ១៣១៩ | ៣២៧.៥ |
| ១៨ | ១៣៣២ | ៣២១.៥ |
| ១៩ | ១៣៤៤ | ៣១៥.៥ |
| ២០ | ១៤១៨ | ១៩០ |
| ២១ | ១៤៤១ | ១៩៤ |
| ២២ | ១៤៤២ | ៣១៦.៥ |
| ២៣ | ១៤៤៣ | ២៨០.៥ |
| ២៤ | ពងមាន់ | ១៦២.៥ |
| ២៥ | ណាំ វ៉ា | ៤០៥ |
| ២៦ | អំបូង | ៣០០.៥ |
| មធ្យម | | **២៨១.១៣៤** |

គេអាចកត់សម្គាល់ថា ៖

- រយៈពេលចាប់ពីដាំរហូតដល់ទុំដែលមានរយៈពេលខ្លីជាងគេគឺ ពូជលេខ ២ មានចំនួន ១៦១ ថ្ងៃ
- រយៈពេលចាប់ពីដាំរហូតដល់ទុំជាមធ្យមរវាងចំនួនថ្ងៃខ្លីជាងគេនិងចំនួនថ្ងៃដែលវែងជាងគេគឺ ២៧៧.៥ ថ្ងៃ
- រយៈពេលចាប់ពីដាំរហូតដល់ទុំមានរយៈពេលវែងជាងគេគឺ ពូជលេខ ៦ មានរយៈពេល ៣៩៤ ថ្ងៃ
- រយៈពេលចាប់ពីដាំរហូតដល់ទុំជាមធ្យមទាំង ២៦ ពូជ មានរយៈពេល ៣០០.៥ ថ្ងៃ ។

យោងតាមលទ្ធផលចំនួនថ្ងៃចាប់ពីដាំរហូតដល់ទុំ ឃើញថាពូជដែលមានរយៈពេលវែងជាងគេគឺ ពូជ លេខ ៦ ហើយពូជ ដែលមានរយៈពេលខ្លីជាងគេគឺ ពូជលេខ ២ ។

### ៣.២.១១ ទម្ងន់ផ្លែក្នុងមួយផ្លែ

ចំពោះការស្រង់ទិន្នន័យទម្ងន់ផ្លែគឺស្រង់នៅពេលផ្លែចេកទុំ ។

**តារាង ១១ : ទម្ងន់ផ្លែក្នុងមួយផ្លែ**

| ពូជ | លេខកូដ | មធ្យម (ក្រាម) |
|---|---|---|
| ១ | ០៣១២ | ៣៧.៦ |
| ២ | ០៥០៤ | ៧០.៦២ |
| ៣ | ០៥០៥ | ០ |
| ៤ | ០៥០៦ | ១០០ |
| ៥ | ០៥៧០ | ១៦១.៩៣ |
| ៦ | ០៦៤៣ | ២៩៧.២២ |
| ៧ | ០៧១២ | ៣៧.៤៨ |
| ៨ | ១១២២ | ២៣២.៩ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ៩៥.៤០ |
| ១១ | ១២៦៥ | ០ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ៧៦.៩៥ |
| ១៤ | ១២៩៦ | ០ |
| ៥ | ១២៩៧ | ២៩៥ |
| ១៦ | ១៣០៧ | ៩២.៧៩ |
| ១៧ | ១៣១៩ | ២៣៦.៨១ |
| ១៨ | ១៣៣២ | ១៨៦.២៥ |
| ១៩ | ១៣៨៤ | ១២០.៨៣ |
| ២០ | ១៤១៨ | ១២១.៧ |
| ២១ | ១៤៤១ | ០ |
| ២២ | ១៤៤២ | ២៦៨.២៨ |

| | | |
|---|---|---|
| ២៣ | ១៤៤៣ | ៣៧.៥ |
| ២៤ | ពងមាន់ | ២១.៦៤ |
| ២៥ | ណាំ វ៉ា | ២៥.៩២ |
| ២៦ | អំបូង | ១៥៥.៦២ |
| មធ្យម | | ១៣១.៦០២ |

គេអាចកត់សម្គាល់ថា :

- ទម្ងន់ផ្លែក្នុងមួយផ្លែ ដែលស្រាលជាងគេគឺ ពូជលេខ ២៤ មានទម្ងន់ ២៨.២៥ក្រាម
- ទម្ងន់ផ្លែក្នុងមួយផ្លែ ដែលមានទម្ងន់ធ្ងន់ជាងគេគឺ ពូជលេខ ២២ មានទម្ងន់ ២៦៨.២៨ក្រាម
- ទម្ងន់ផ្លែក្នុងមួយស្ទួងជាមធ្យមទាំង ២៦ ពូជ គឺ ១៣១.៦០២ ក្រាម

យោងតាមលទ្ធផលទម្ងន់ផ្លែក្នុងមួយផ្លែ យើងឃើញថាពូជដែលមានទម្ងន់ផ្លែស្រាលជាងគេគឺ ពូជលេខ ២៤ ហើយពូជ ដែលមានទម្ងន់ធ្ងន់ជាងគេគឺ ពូជលេខ ២២ ។

**៣.១.១២ ទម្ងន់ផ្លែក្នុងមួយស្ទួង**

ចំពោះការស្រង់ទិន្នន័យទម្ងន់ផ្លែគឺស្រង់នៅពេលផ្លែចេកទុំ ។

**តារាង ១២ : ទម្ងន់ផ្លែក្នុងមួយស្ទួង**

| **ពូជ** | **លេខកូដ** | **មធ្យម (គ.ក)** |
|---|---|---|
| ១ | ០៣១២ | ៣.៩ |
| ២ | ០៥០៤ | ២.៨ |
| ៣ | ០៥០៥ | ០ |
| ៤ | ០៥០៦ | ១៥.០៥ |
| ៥ | ០៥៧០ | ២៨.២៥ |
| ៦ | ០៦៤៣ | ១១.៨៥ |
| ៧ | ០៧១២ | ៥.៦ |
| ៨ | ១១២២ | ២៦.៥ |
| ៩ | ១១២៣ | ០ |
| ១០ | ១២៦៤ | ៩.៣ |
| ១១ | ១២៦៥ | ០ |
| ១២ | ១២៨២ | ០ |
| ១៣ | ១២៨៣ | ១៣.២៥ |

| | | |
|---|---|---|
| ១៤ | ១២៩៦ | ០ |
| ១៥ | ១២៩៧ | ២៧.៧៥ |
| ១៦ | ១៣០៧ | ៧.៤៥ |
| ១៧ | ១៣១៩ | ២១.៥ |
| ១៨ | ១៣៣២ | ១៤.៧ |
| ១៩ | ១៣៤៤ | ៤.៣៥ |
| ២០ | ១៤១៨ | ១៥.៤ |
| ២១ | ១៤៤១ | ០ |
| ២២ | ១៤៤២ | ៩.៣៥ |
| ២៣ | ១៤៤៣ | ៣ |
| ២៤ | ពងមាន់ | ៣.៩៥ |
| ២៥ | ណាំ វ៉ា | ២៣.៧៥ |
| ២៦ | អំបូង | ៥.៩ |
| មធ្យម | | **២១.៥៦០** |

គេអាចកត់សម្គាល់ថា :

- ទម្ងន់ផ្លែក្នុងមួយស្ទងដែលស្រាលជាងគេគឺ ពូជលេខ ២ មានទម្ងន់ ២.៨ គ.ក្រ
- ទម្ងន់ផ្លែក្នុងមួយស្ទងជាមធ្យមប្រមាណ ១៥.៥២ គ.ក្រ គឺពូជលេខ ២ និងពូជលេខ ៥
- ទម្ងន់ផ្លែក្នុងមួយស្ទងដែលធ្ងន់ជាងគេគឺ ពូជលេខ ៥ មាន ទម្ងន់ ២៨.២៥ គ.ក្រ
- ទម្ងន់ផ្លែក្នុងមួយស្ទងជាមធ្យមទាំង ២៦ ពូជ គឺ ២១ គ.ក្រ ។

យោងតាមលទ្ធផល យើងឃើញថាពូជដែលមានផ្លែធ្ងន់ជាងគេគឺ ពូជ លេខ ៥ ហើយពូជ ដែលមានទម្ងន់ស្រាលជាងគេគឺ ពូជលេខ ២ ។

## ៣.២ ការពិភាក្សា

ការសិក្សាប្រៀបធៀបពូជចេកទាំង ២៦ បានបង្ហាញឱ្យឃើញថា :

- ពូជដែលមានកំពស់ខ្ពស់ជាងគេគឺ ពូជលេខ ២៥ ពូជដែលមាន កំពស់ទាបជាងគេគឺ ពូជលេខ ១២
- ពូជដែលមានប្រវែងស្លឹកវែងជាងគេគឺ ពូជលេខ ១១ ពូជដែលមានប្រវែងស្លឹកខ្លីជាងគេគឺ ពូជលេខ ១៥
- ពូជដែលមានចំនួនស្លឹកច្រើនជាងគេគឺ ពូជលេខ ២ ពូជដែលមានចំនួនស្លឹកតិចជាងគេគឺ ពូជលេខ ២១
- ពូជដែលមានប្រវែងផ្លែវែងជាងគេគឺ ពូជលេខ ១៨ ពូជដែលមានប្រវែងផ្លែខ្លីជាងគេគឺ ពូជលេខ ២៤
- ពូជដែលមានចំនួនផ្លែច្រើនជាងគេគឺ ពូជលេខ ១៣ ពូជដែលមានចំនួនផ្លែតិចជាងគេគឺ ពូជលេខ ១៣

- ពូជដែលមានចំនួនកូនបែកច្រើនជាងគេគឺ ពូជលេខ ៧ ពូជដែលមានចំនួនកូនបែកតិចជាងគេគឺ ពូជលេខ ៣ និងពូជលេខ ១២
- ពូជដែលមានរយៈពេលចាប់ពីថ្ងៃធ្លាក់ត្រយូងដល់ទុំវែងជាងគេគឺ ពូជលេខ ១៣ និង ពូជ ដែលមាន រយៈពេលខ្លីជាងគេគឺ ពូជលេខ ៣ និងពូជលេខ ២៣
- ពូជដែលមានរយៈពេលចាប់ពីថ្ងៃដាំរហូតដល់ចេញត្រយូងវែងជាងគេគឺ ពូជ លេខ ១១ និងពូជ ដែលមាន រយៈពេលខ្លីជាងគេគឺ ពូជលេខ ២៤
- ពូជដែលរយៈពេលចាប់ពីថ្ងៃដាំរហូតដល់ចេញត្រយូងវែងជាងគេគឺ ពូជ លេខ ៥ និងពូជ ដែលមានរយៈ ពេលខ្លីជាងគេគឺ ពូជលេខ ២
- ពូជដែលរយៈពេលចាប់ពីថ្ងៃដាំរហូតដល់ទុំវែងជាងគេគឺ ពូជ លេខ ៦ ហើយ ពូជដែលមានរយៈពេលខ្លី ជាងគេគឺ ពូជលេខ ២ ។

បើគិតវដ្តជីវិតរបស់ដំណាំចេក គឺចាប់ពីថ្ងៃដាំកូនចេកដែលមានកំពស់ ២៥ សង្ទីម៉ែត្រ ក្នុងអាយុកាល ២៥ ថ្ងៃ បន្ទាប់ពីថ្ងៃបណ្តុះជាលិកា រហូតដល់ថ្ងៃដែលចេកទុំលើដើម ពូជចំនួន ២០ ត្រូវជា ៧៦.៩២ ភាគរយ បានផ្តល់ផល និង ពូជចំនួន ០៦ ទៀតពុំបានផ្តល់ទេ ប៉ុន្តែការសិក្សាពុំបានបន្តលើពូជចុងក្រោយនេះ ដោយគុម្ពចេកបានរីកធំនាំឱ្យចង្អៀត ចន្លោះគុម្ព និងពូជចេកទាំនោះស្ថិតក្នុងសភាពមិនមាំមួន គឺពូជលេខ ៣ . ៩ . ១១ . ១២ . ១៤ និង ២១ ។

ជាទូទៅយើងអាចកំណត់បានអំពីលក្ខណៈ សម្បត្តិល្អរបស់ពូជចេកគឺ :

- អាយុកាលខ្លី គឺពូជលេខ ២
- ផ្លែវែងល្អ គឺពូជ ចេកលេខ ១៨
- ចំនួនផ្លែចេកច្រើននិងល្អក្នុង ១ ស្និត គឺពូជលេខ ១៣
- ទម្ងន់ផ្លែក្នុងមួយផ្លែខ្ពស់ជាងគេគឺ ពូជលេខ ២២
- ទម្ងន់ផ្លែក្នុងមួយស្និតខ្ពស់ជាងគេគឺ ពូជលេខ ៥
- ពូជមានរស់ជាតិ ឆ្ងាញ់ជាងគេគឺ ពូជលេខ ៤ ដែលមានរសជាតិផ្អែម ក្លិនក្រអូបឈ្ងុយស្រាល
- ពូជលេខ ៧ មានរសជាតិផ្អែមឈ្ងុយ
- ពូជលេខ ១០ មានរសជាតិផ្អែមឈ្ងុយ
- ពូជលេខ ២០ មានរសជាតិរសជាតិផ្អែមឈ្ងុយ
- ពូជលេខ ១៥ មានរសជាតិផ្អែមស្រាល ។

# សេចក្ដីសន្និដ្ឋាន

ការសិក្សានេះបានគ្របដណ្ដប់តែទៅលើវដ្ដជីវិតនៃដើមចេកមេ គឺក្នុងរយៈពេលចាប់ពីដាំកូនដែលមានកំពស់ត្រឹមតែ ២៥ សង់ទីម៉ែត្រ រហូតដល់ពូជមួយមានផ្លែទុំ ដោយពុំបានសិក្សានូវពូជចេកពុំទាន់ផ្ដល់ផលបន្ទាប់ទៀត ។

លទ្ធផលនៃការពិសោធន៍ក៏បានបង្ហាញឱ្យឃើញថា ក្នុងចំណោមពូជចេកទាំង ២៦ មានតែចំនួន ០៦ ពូជពុំបានផ្ដល់ផលនៅឡើយទេ ។ ទោះយ៉ាងណាចេក ២០ ពូជ ត្រូវជា ៧៦.៩២ ភាគរយ បានផ្ដល់ផល ដែលក្នុងនោះ ពូជចេកមានអាយុកាល ឬវដ្ដជីវិតមានរយៈពេល ១៦១ថ្ងៃ ខ្លីជាងគេ និង ៣៩៤ វែងជាងគេ។ ពូជលេខ ១៨ ផ្ដល់ផ្លែវែងល្អ ។ ពូជលេខ ១៣ មានផ្លែច្រើន និងល្អក្នុងមួយស្ទង ប៉ុន្តែពូជលេខ ១៥ មានទម្ងន់ផ្លែក្នុងមួយស្ទងធ្ងន់ជាងគេ ។ រីឯពូជលេខ ៤ ៧ ១០ ២០ មានរសជាតិផ្អែមល្ហុយ និងពូជលេខ ១៥ មានរសជាតិផ្អែមស្រាល ប៉ុន្តែពុំអាចប្រៀបធៀបទៅនឹងរសជាតិផ្លែចេកទុំនៃពូជក្នុងស្រុក ដូចជាពូជលេខ ២ . ៤ និង ២៦ បានឡើយ ។ ក្រៅពីនេះពូជចេកផ្ដល់ផ្លែទំហំ ធម្មតា និងទម្ងន់ប្រហាក់ប្រហែលគ្នាមានចំនួន ៥ ភាគរយ និងមានរស់ជាតិមិនផ្អែមមិនក្រអូប ៣៥ ភាគរយ ។ ផ្លែចេកទុំរបស់ពូជក្រោយនេះមានរស់ជាតិសាបបន្តិចមែន ប៉ុន្តែគេអាចបរិភោគផ្លែចេកនេះក្នុងរូបភាពជាអាហារកែច្នៃផ្សេង ។ ដោយឡែកក្បែត្របរិស្ថាន នៅសួនដំណាំសាលាជាតិកសិកម្មព្រែកលៀបបានអនុគ្រោះដល់ពូជចេកនាំចូលចំនួន ១៧ ត្រូវជា ៧៣.៩១ ភាគរយ បានដុះលូតលាស់ ផ្ដល់ផល និងបន្តពូជបានល្អ ។

ដោយគោលបំណងផ្ដោតទៅលើលក្ខណៈជីវសាស្ត្រ ការផ្ដល់ផ្លែ និងគុណភាពរសជាតិនៃដំណាំចេក ២៦ ពូជ លទ្ធផលនៃការសិក្សានេះស្ថិតនៅតែជាទិន្នន័យ និងព័ត៌មានមូលដ្ឋានបណ្ដោះអាសន្ន ព្រោះការសិក្សាបានដំណើរការតែមួយវដ្ដជីវិត និងពុំទាន់បានវិភាគគុណភាពរសជាតិដោយប្រើឧបករណ៍វិទ្យាសាស្ត្រនៅឡើយ ។


ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ
សាលាជាតិកសិកម្មព្រែកលៀប